# បុព្វចរិយាដែលមានលក្ខណៈរង្វើលនៃរបាំរាំថ្វាយអ្នកតា ក្នុងរបាំរដឹមស្រុកហៃ

*អត្ថបទដោយ ឈួរ យ៉ុងផេង CHHUOR Yingpheng*

*អត្តសញ្ញាណ* គឺជាពាក្យមួយដែលប្រកបទៅដោយ ទ្វេចរភាព (ambiguous) ឬ អ័ព្ទភាព (obscure) ដែលមនុស្សនីមួយៗតែងមាននិយមន័យផ្សេងៗពីគ្នា។ បើទោះបី *អត្តសញ្ញាណ* មិនមានជាសភាវសណ្ឋិតនៅនឹងថ្កល់ ឬ ជាឯករចនភាពក៏ដោយ ក៏វាត្រូវបានគេប្រើប្រាស់ជាកត្តា ឬជារង្វាស់ក្នុងការប្រៀបធៀប បែងចែក ឬ ធ្វើចំណាត់ថ្នាក់ ជាតិសាសន៍មួយទៅជាតិសាសន៍មួយទៀតផងដែរ។ ជាទូទៅ គេអាចសម្គាល់អត្តសញ្ញាណមនុស្សមួយក្រុម ឬជាតិសាសន៍មួយក្រុម តាមរយៈពំនោលនៃវប្បធម៌ សិល្បៈ (រូបី និង អរូបី) ជំនឿសាសនា សំលៀកបំពាក់ និងភាសា ដែលសមាសធាតុទាំងនេះហើយបង្កើតឱ្យមាននូវអ្វីដែលយើងហៅថា *ឯកលក្ខណភាព* នៃជាតិសាសន៍។ ជាក់ស្តែង *ឯកលក្ខណភាព ទ្វេចរភាព* និង *អត្តសញ្ញាណ* ត្រូវបានគេលើកមកពិភាក្សានៅក្នុងមហោស្រពរដូវកាលវប្បធម៌ឆ្នាំ២០២០ ដែលរៀបចំឡើងដោយអង្គការសិល្បៈខ្មែរអមតៈ ក្រោមប្រធានបទ *រដូវវប្បធម៌៖ ការបង្ហាញអត្តសញ្ញាណ "ពួកគេ និង/ឬ ពួកយើង"*។ សិល្បៈជាច្រើនទម្រង់ ដូចជា ទម្រង់បុរាណ ប្រជាប្រិយ សហសម័យ ល្ខោននិយាយ ឃីកេ។ល។ បានចូលរួមត្រៀមខ្លួនសម្រាប់ឆ្លើយតបទៅនឹងតម្រូវការនៃប្រធានបទខាងលើ។ នៅក្នុងទម្រង់ទាំងនោះ មានទស្សនីយភាពមួយដែលក្រោយដំឡើងក្លាយជាសមិទ្ធផលនៃសិល្បៈ (ប្រពៃណីវប្បធម៌ដែលគេបំលែងឱ្យក្លាយជាសិល្បៈ) នៃជនជាតិ"កួយ" បានធ្វើឱ្យយើងភ្ញាក់ផ្អើល ហើយផ្តល់ជាឱកាសមួយសម្រាប់យើងស្វែងយល់ពីអត្តសញ្ញាណខ្លះៗនៃជនជាតិនេះតាមរយៈរបាំ។

***រដឹមស្រុកហៃ*** (មានន័យថា *ប្រពៃណីភូមិខ្ញុំ* ជាភាសាខ្មែរ) ជាទស្សនីយភាពមួយដែលរៀបរាប់អំពីជីវភាព ជំនឿ ភាសា និងព្រលឹងវប្បធម៌នៃជនជាតិ "កួយ" ដោយមានការចូលរួមសម្តែងពីសិល្បករ សិល្បការី ចំនួន២០រូបមកពីសហគមន៍ជនជាតិកួយ ភូមិទន្សោង ខេត្តស្ទឹងត្រែង។ ទស្សនីយភាពទាំងមូលនៃរបាំ ត្រូវបានបែងចែកជា៧កម្មវិធីរបាំតូចៗដូចជា៖ *របាំរាំសែនគ្រូមុនសម្តែង របាំរាំថ្វាយអ្នកតា របាំកាធារ របាំអុំទូក របាំនាងក្រពុំឈូក របាំជូនពរ និងរបាំលា-*

*ទស្សនិកជន*។ ក្នុងនោះយើងកត់សម្គាល់ឃើញថា *របាំរាំថ្វាយអ្នកតា* មានលក្ខណៈពិសេសមួយដែលធ្វើឱ្យយើងចាប់អារម្មណ៍ជាខ្លាំង។ ដូចនេះចំពោះអត្ថបទដែលអធិប្បាយខាងក្រោម ក៏ដូចជាទំហំ ឬផែននៃពាក្យ *អត្តសញ្ញាណ* ដែលយើងនឹងសំដៅទៅ គឺចំពោះតែការសម្តែងលើឆាកអំពី *របាំរាំថ្វាយអ្នកតា* តែប៉ុណ្ណោះ។ ហើយយើងនឹងសាកល្បងឆ្លើយនឹងសំនួរដែលបានចោទសួរថា តើយើងអាចប្រទះឃើញពីចំនុចយ៉ាងហោចណាខ្លះនៃអត្តសញ្ញាណជនជាតិ "កួយ" តាមរយៈរបាំនេះ?

មុនឈានចូលដល់ការវិភាគ យើងគប្បីងាកមកស្វែងយល់អំពីដំណើរសាច់រឿងនៃរបាំសិន។ ជាដំបូងនៃរបាំ គឺប្រព្រឹត្តទៅដោយមានជំងឺ(មានអាការៈឈឺធ្មេញ)មកបៀតបៀនក្មេងស្រីភូមិម្នាក់។ យើងអាចសម្គាល់នាងបាន ដោយនាងស្លៀកអាវក្រណាត់វែងពណ៌ខៀវចាស់ សំពត់សឹងផ្កាឈូកសូកពីក្នុងចង្កេះព័ទ្ធដោយក្រណាត់ក្រហមបត់មកមុខ សក់បួងឡើងលើលំអដោយក្រណាត់ប៉ាក់អង្កាំពណ៌ក្រហមចងទៅក្រោយ ខ្សែក ខ្សែដៃអង្កាំពណ៌ស ក្រហមជាច្រើនពណ៌ និងក្រវិលធ្វើឡើងពីរុក្ខជាតិក្រៀមម៉្យាង។ នាងទទេជើង ហើយស្លៀកពាក់មិនសូវខុសប្លែកគ្នាពីសំលៀកបំពាក់របស់តួអង្គស្ត្រីភេទដទៃទៀត។ ក្រោយពីមានអាការៈជំងឺជាច្រើនថ្ងៃ នាងក៏ត្រូវបានអ្នកភូមិប្រុសស្រី២នាក់ដែលមានវ័យកណ្តាល និងម្ចាស់ស្រុកស្រីម្នាក់ដែលមានសម្បុរស្រអែម វ័យចំណាស់បន្តិច ដឹកនាំមកសុំអន្តរាគមន៍ពីអ្នកសច្ចំ។ អ្នកសច្ចំ ដែលត្រូវជាអ្នកនាំសារនៃអ្នកភូមិ និង *អ្នកតា* អង្គុយនៅកណ្តាលវង់ មានប្រដាប់ប្រដាសែនដោយមានទៀនអុជនៅចំកណ្តាលចាន បានធ្វើការគន់គូរ តើក្មេងស្រី ឬអ្នកភូមិ បានប្រព្រឹត្តអំពើខុសឆ្គងអ្វីទៅលើ [ដែលក្នុងអត្ថន័យកួយ និងខ្មែរសំដៅទៅលើ] *អ្នកតា* ប្រចាំស្រុក។ បន្ទាប់មកគាត់បានបញ្ជាក់ពីរបៀបព្យាបាលជំងឺនេះដោយនិយាយជាភាសាកួយថា៖ 'ប្រសិនបើអ្នកភូមិខុសឆ្គងលើ *អ្នកតា* នោះអ្នកភូមិត្រូវរៀបចំពិធីដង្វាយរាំថ្វាយអ្នកតា។ ផ្ទុយទៅវិញ ប្រសិនអ្នកភូមិមិនមានកំហុសឆ្គង ឬប្រឈមមុខនឹងជំងឺដែលអ្នកសច្ចំគន់គូរថាមិនមែនមកពី *អ្នកតា* នោះ ពួកគេមិនចាំបាច់រៀបចំពិធីឡើយ'។ ជាក់ស្តែង ក្រោយការគន់គូរហើយឃើញថាអ្នកភូមិពិតជាខុសឆ្គងលើ *អ្នកតា* ដូច្នេះអ្នកភូមិត្រូវរៀបចំពិធីដើម្បីរាំថ្វាយ *អ្នកតា*។

បន្ទាប់មក យើងឃើញពួកគេរៀបចំសំណែន បទភ្លេង និងរបាំរាំថ្វាយ ដោយសំណែនមានដង្វាយមួយល្អីដាក់នៅមុខហើយកណ្តាលឆាក ឯរានសក្ការៈត្រូវបានដាក់នៅខាងឆ្វេងដៃនៃឆាក (រាប់ពីអ្នកសម្តែងលើឆាក)។ បទភ្លេងដែលគេប្រគំ ត្រូវបានលេងដោយសំឡេងស្គរ និងទ្រ។ ចំពោះពិធីរាំថ្វាយទាំងមូលវិញ យើងឃើញមានការចែកការរាំជា៣ក្រុមតួអង្គ។ ក្រុមទី១ គឺក្រុមតួអង្គចាស់ព្រឹទ្ធាចារ្យប្រុសស្រីមួយគូ ចាប់ផ្តើមរាំមុនគេ ដោយអ៊ំប្រុសលេងក្រាប់នៅក្នុងដៃ ហើយអ៊ំស្រីរាំទៅ

តាមចង្វាក់ភ្លេងនៅចំពោះមុខពានសក្ការៈតូចមួយដែលធ្វើពីឈើក្រាលដោយកន្ទេលគែមក្រហម ហើយអុជធូប និងទៀនជុំវិញ (រូបទី១) ។ ក្រុមទី២ គឺក្រុមតួអង្គក្មេងប្រុស២នាក់ រាំបន្ទាប់ពីក្រុមទី១ លេងគុនដំបង ដើម្បីផ្តល់ជា "កម្លាំង" សម្រាប់ប្រយុទ្ធប្រឆាំងនឹងជំងឺ។ ក្រុមទី៣ គឺតួអង្គស្ត្រីភេទ ដែលលាយឡំដោយចាស់ក្មេង កំពុងរាំហែរហម ប្រៀបដូចជា "កងជំនួយ" សម្រាប់ផ្តល់ជាកម្លាំង កាយ ជាកម្លាំងចិត្តដល់ក្រុមអ្នករាំទាំងមូល (រូបទី២)។ ក្បាច់រាំរបស់តួអង្គស្ត្រី គឺបង្វិលចុងដៃស្រដៀង ទៅនឹងរាំក្បាច់របស់ខ្មែររួចច្រត់ទៅលើចង្កេះ ហើយទាំង៣ក្រុមទះដៃព្រមគ្នាកាលណាសំឡេងភ្លេង ឈានដល់ចំនុចមួយ។ ពួកគេផ្សំផ្គុំគ្នារាំ បង្កើតជាកម្លាំងធំមួយដើម្បីសម្រេចពិធីនេះ។





រូបទី១. ពានសក្ការៈ



រូបទី២. លក្ខណៈនៃរបាំទាំងមូល

ឆ្លងកាត់តាមការអធិប្បាយនៃលក្ខណៈរបាំខាងលើ យើងមើលឃើញថា បទដ្ឋានគុណភាព កម្រិត "ខ្ពស់" នៃរបាំ "ស្តង់ដារ" ដែលរមែងមានសភាពជា "ម៉ឺងម៉ាត់" មានការហាត់សម តឹងរឹង ស្រុះគ្នានេះ អាចនិយាយបានថាមិនសូវមានឥទ្ធិពលលើ *របាំរាំថ្វាយអ្នកតា* នេះទេ ។ ដោយជាក់ស្តែង *របាំរាំថ្វាយអ្នកតា* ភាគច្រើនស្តែងឱ្យឃើញពីភាពរង្វើល ងាយបត់បែននៃជីវភាពដើម និងការរក្សាលំនឹងយេនឌ័រនៃកុលសម្ព័ន្ធ ដែលបានប្រឈមជាមួយនឹងមជ្ឈដ្ឋានរស់នៅអស់រយៈកាលជាយូរ ប៉ុន្តែមិនមែនអំពីអ្វីដែលបានលត់ដំក្លាយជា "ច្បាប់ទម្លាប់" មាន "បទដ្ឋានតឹងរឹង" ឬ ដែលយើងតែងយល់ថាជា "ភាពមានអរិយធម៌" ឡើយ។ សភាពរង្វើល ងាយបត់បែននៃជីវភាពដើម និងការរក្សាលំនឹងយេនឌ័រនៃកុលសម្ព័ន្ធដែលជាបុព្វចរិយារបស់មនុស្សនេះ បានទាញឱ្យយើងរកឃើញពីលក្ខណៈពិសេសមួយនៃ *របាំរាំថ្វាយអ្នកតា* ។ លក្ខណៈពិសេសនោះគឺ ក្នុងផ្ទៃរបាំទាំងមូលមានសភាពងាយបត់បែន ហើយមានលក្ខណៈរង្វើលដែលចែកជា៣ចំនុចដូចជាៈ ទី១.អាយុ និងយេនឌ័រនៃតួអង្គមិនមានភាពស្របាលគ្នា ទី២.ជំនួស និងបំលាស់ប្តូរតួអង្គដែលមានភាពបត់បែន និងទី៣. ភាពមិនចាំបាច់មានលក្ខណៈជារួមធំមួយ។

## ១. អាយុ និងយេនឌ័រនៃតួអង្គមិនមានភាពស្របាលគ្នា

ក្រឡេកមើលទៅ*របាំរាំថ្វាយអ្នកតា* ម្តងទៀត យើងកត់សម្គាល់ឃើញថា របាំនេះត្រូវបានសម្តែងដោយក្រុមមនុស្ស៣ក្រុមដែលមិនមានវ័យស្មើគ្នា ហើយមានយេនឌ័រមិនដូចគ្នា។ ក្នុងនោះ អ្នកសម្តែងរាំមុខរានសក្ការៈ អ្នកវាយគុនដំបង និង អ្នករាំដង្វាយ មានពីវ័យកុមារ វ័យកណ្តាល រហូតដល់វ័យចំណាស់។ ការជ្រើសរើស និងដាក់តាំងតួអង្គបែបនេះ វាមិនត្រឹមតែបង្ហាញពីលក្ខណៈ "អត់អោន" ឬ មិនប្រកាន់ច្រើនចំពោះពិធីដែលមានក្នុងរបាំទេ (ឧទា. ប្រៀបធៀបជាមួយរបាំ "ស្តង់ដារ" ដែលភាគច្រើន ភាគីខាងក្រោយនេះ តែងមានការជ្រើសតាំងតួអង្គដែលមានអាយុ និងយេនឌ័រមិនសូវខុសគ្នាច្រើន។) ហើយថែមទាំង បកស្រាយឱ្យឃើញពីជំនឿ និងជីវិតអ្នកភូមិផ្ទាល់ដែលរមែងមានពិធីបុណ្យដែលត្រូវបានចូលរួមជាសមូហភាព។

ការចូលរួមពីគ្រប់មជ្ឈដ្ឋានរស់នៅរបស់មនុស្សនេះ បានដើរតួជាមូលន័យធំមួយ សម្រាប់កំនត់ទិសដៅផ្លូវទៅរបស់របាំ ដោយជាក់ស្តែងវាបានជះឥទ្ធិពលមករបាំ ធ្វើឱ្យផ្ទៃនៃរបាំទាំងមូលមានសភាពជាងាយបត់បែន និងរស់រវើក ។ ត្រង់នេះន័យដែលថា «ងាយបត់បែន និងរស់រវើក» ពុំ

មានន័យស្មើនឹង "ងាយបត់បែន និងរស់រវើក" នៅក្នុងរបាំ "ស្តង់ដារ" ឡើយ ព្រោះថា អត្ថន័យខាងមុខសំដៅទៅលើភាពរស់រវើកដែលមានលក្ខណៈជារង្វើលដោយពុំសូវពឹងផ្អែកលើបទដ្ឋានជាក់លាក់មួយ ឯអត្ថន័យខាងក្រោយសំដៅទៅលើភាពរស់រវើកមានលក្ខណៈជាស្រុះគ្នាដោយពឹងផ្អែកលើបទដ្ឋានជាក់លាក់មួយ។ ឧទា. សិល្បករ សិល្បការី ដែលសម្តែងក្នុង*របាំរាំថ្វាយអ្នកតា* មិនប្រាកដថាជាអ្នកសម្តែងអាជីព។ ដូច្នេះ បញ្ហាខ្វះមនុស្ស មិនដាក់កំហិតលើមនុស្ស និងផ្លាស់ប្តូរមនុស្សមិនទៀង ។ល។ កំនត់ធ្វើឱ្យរបាំនេះមានភាពរង្វើលក្នុងការជ្រើសតាំងតួអង្គ និងការផ្លាស់ប្តូរសាច់រឿងសម្តែងជាក់ស្តែង។ ឯចង្វាក់ដែលតួអង្គទាំងអស់រាំនៅក្នុង *របាំរាំថ្វាយអ្នកតា* សុទ្ធមិនសូវមានសភាព "ស្រុះគ្នា" ហើយប្រើក្បាច់ដដែលៗ ឬតែមួយ បន្ទាប់មកបញ្ចេញក្បាច់តាមតែកាយវិការខ្លួនធ្វើបាន។ ការបញ្ចេញកាយវិការតាមតែខ្លួនធ្វើនេះទៀតសោត គឺជា លក្ខណៈរង្វើល ដែលផ្តល់អារម្មណ៍ឱ្យយើងយល់ថា របាំនេះមានសភាពដូច "របាំប្រជាប្រិយខ្មែរ" (រាំវង់...) ជាជាង "របាំទម្រង់ហ្លួង"។ ដូចនេះ បញ្ហាខ្វះ ឬមិនកំហិតលើមនុស្សដែលជាហេតុធ្វើឱ្យតួអង្គមានវ័យ និងយេនឌ័រមិនស្មើគ្នា ចង្វាក់រាំដែលមិនសូវមានភាព "ស្រុះគ្នា" ហើយក្បាច់រាំដដែលៗ ឬតែមួយដែលធ្វើឱ្យតួអង្គបញ្ចេញក្បាច់តាមតែខ្លួនធ្វើបាននេះ ជាអ្វីដែលខាងលើនិយាយថា ភាពរស់រវើកបែបមិនសូវពឹងផ្អែកលើបទដ្ឋានជាក់លាក់មួយ។

ដូច្នេះ ចំពោះលក្ខណៈរង្វើលដែលមានភាពបត់បែន រស់រវើក មិនដាក់កំហិតចំពោះអាយុ និងយេនឌ័រតួអង្គនេះ បានធ្វើឱ្យយើងប្រិចភ្នែកឃើញខ្លះៗពីសង្គមនៃជនជាតិ "កួយ" ដែលយើងអាចទាញថា ពួកគេជា "សង្គម" មួយដែលមិនប្រកាន់ច្រើន ហើយលាយឡំ និងប្រសព្វគ្នាទៅដោយមនុស្សគ្រប់ស្រទាប់វណ្ណៈ។

## ២.ជំនួសនិង បំលាស់ប្តូរតួអង្គដែលមានភាពបត់បែន

ក្រៅពី មិនរឹតត្បិតចំពោះ អាយុ និងយេនឌ័រនៃតួអង្គ។ លក្ខណៈរង្វើលពិសេសមួយទៀតនៃ *របាំរាំថ្វាយអ្នកតា* គឺរបាំនេះអាចជំនួស ឬផ្លាស់ប្តូរតួអង្គបានតាមកាលៈទេសៈ។ ដូចដែលខាងលើបានរៀបរាប់ស្រាប់ របាំនេះត្រូវបានដកស្រង់ពីជីវភាព និងវប្បធម៌ជាក់ស្តែងរបស់ជនជាតិ។ ដូចនេះ ភាពបត់បែនតាមកាលៈទេសៈរបស់ជីវិតពិតរបស់មនុស្សប្រាកដជាត្រូវបានគោរព ហើយអនុម័តនៅក្នុងរបាំ។ ជាក់ស្តែង តួអង្គអ្នកសច្ឆំ តួអង្គក្មេងប្រុសវាយគុនដំបង និងតួអង្គចាស់ព្រឹទ្ធាចារ្យរាំមុខរានសក្ការៈ សុទ្ធជាតួអង្គដែលអាចជំនួសបាន។ ក្នុងន័យនេះ យើងពុំបានសំដៅទៅគំនិតដែលនិយាយ

ថា "របាំទាំងមូលអាចផ្លាស់ប្តូរតួអង្គទាំងអស់បានទេ" ព្រោះថាពាក្យ *របាំ* គេរមែងចាត់ថ្នាក់ទៅក្នុង *សិល្បៈ* ឯរឿងរាល់ *សិល្បៈ* រមែងខុសប្លែកខ្លះៗពីជីវភាពពិត។ ឧទា. យើងប្រហែលមិនអាចនិយាយថា តួអង្គក្រុមស្ត្រីរាំដង្វាយអាចជំនួស ដោយក្រុមបុរសភេទទេ ព្រោះវាមិនមានន័យស្មើគ្នា។ ដូចនេះ អ្វីដែលយើងនិយាយថា ការជំនួសនិងផ្លាស់ប្តូរតួអង្គតាមកាលៈទេសៈ គឺចង់សំដៅទៅលើតួអង្គដែលអាចផ្លាស់ប្តូរបាន ហើយតួអង្គនេះទៀតសោត គឺពិតជាមានវត្តមាននៅក្នុងជីវិតជាក់ស្តែង។

ជាក់ស្តែង មុននឹងឈានដល់ពិធី *របាំរាំថ្វាយអ្នកតា* យើងឃើញមានចាស់ព្រឹទ្ធាចារ្យ និងម្ចាស់ស្រុកអង្គុយជំនុំជាមួយនឹងអ្នកសច្ចំដែលជាស្ត្រីភេទ។ អ្នកសច្ចំនេះផ្ទាល់គឺជាតួអង្គមួយដែលអាចជំនួសបានតាមកាលៈទេសៈ ត្បិតជាដំបូងឡើយនៃរបាំ គេកំនត់យកបុរសភេទជាតួ។ ប៉ុន្តែអ្វីដែលសំខាន់គឺថា មិនខ្វល់ថាទម្រង់នៃរបាំក្តី មិនខ្វល់ថាទស្សនិកជនក្តី ការដើរតួអ្នកសច្ចំជាស្ត្រីភេទបញ្ជាក់ថាពុំមានការប៉ះពាល់ដល់ផ្ទៃរបាំ និងទស្សនិកជនទេ ព្រោះថាគេពិតជាអាចរកឃើញវត្តមានតួអង្គនេះនៅជីវភាពជាក់ស្តែង និងសិល្បៈបានមែន។

ឯចំពោះក្រុមក្មេងវាយគុនដំបង និង តួអង្គចាស់ព្រឹទ្ធាចារ្យរាំមុខរានសក្ការៈវិញ យើងឃើញថា ភាគច្រើនវាទាក់ទងទៅនឹងបញ្ហាតថភាពជាក់ស្តែង និងលទ្ធភាពដែលអាចធ្វើទៅបានរបស់តួអង្គ។ ឆ្លងតាមការសាកសួរខ្លះៗ។ យើងបានទទួលព័ត៏មានថា ៖ 'ក្រុមវាយគុនដំបងនេះ អាចជំនួសដោយក្រុមក្មេងស្រីវាយដំបងបាន ប៉ុន្តែដោយស្ថានភាពជាក់ស្តែង ពួកគាត់ពុំទាន់បង្ហឹកបានក្រុមក្មេងស្រី'។ ហើយពួកគាត់ក៏បានបន្ថែមទៀតថា៖ 'ថ្វីនិយាយថាអាចផ្លាស់ប្តូរបានមែន ប៉ុន្តែវាមិនមានសភាពជាចាំបាច់ ព្រោះថានៅក្នុង *សិល្បៈ* រៀងរាល់តួអង្គដែលពាក់ព័ន្ធនឹង *កម្លាំង* គេរមែងនឹកឃើញនិងទាក់ទងដល់តួអង្គបុរសភេទ ឯការជ្រើសរើសកុមារមិនមែនមនុស្សប្រុសជំទង់វិញ គាត់បានបន្ថែមទៀតថាគឺ ដើម្បីបន្តវេន'។ ដូចនេះចំពោះការដែលនិយាយថា តួអង្គក្មេងប្រុសវាយគុនដំបងអាចជំនួសបាន គឺភាគច្រើនឈរនៅលើជំហរតថភាពជាក់ស្តែងរបស់ពួកគេ មិនមែនដើម្បីផ្លាស់ប្តូរដើម្បីតែផ្លាស់ប្តូរទេ។

រីឯចំពោះតួអង្គចាស់ព្រឹទ្ធាចារ្យរាំមុខរានសក្ការៈវិញ ជាក់ស្តែងគឺតួអង្គអ៊ំប្រុសលេងក្រាប់ក្នុងដៃ។ យើងឃើញថា នៅពេលដែល ការសំដែងពិតបានប្រព្រឹត្តទៅ គាត់បែរជាអវត្តមានទៅវិញ ដោយសារបញ្ហាផ្ទាល់ខ្លួនជាមួយរោគា។ ការបាត់ ឬមិនបានជំនួសដោយតួអង្គផ្សេងនៃគាត់ មិនថាសម្រាប់របាំទាំងមូលក្តី ឬសម្រាប់ទស្សនិកជនក្តី សុទ្ធតែមិនបានរង្គោះរង្គើខ្លាំងពេកចំពោះផ្ទៃនៃរបាំទាំងមូលឡើយ។ ដោយហេតុជាក់ស្តែងបញ្ជាក់ប្រាប់ថា វាមិនមានភាពអន្តរាយទេ នៅពេលដែល

ទស្សនិកជន មើលអំស្រីមុខរាមសក្ការៈកំពុងរាំតែម្នាក់ឯង។ ដូចនេះចំពោះ ការដែលមិនជំនួសឡើងវិញនៃតួអង្គអំប្រុស គឺភាគច្រើនឈរលើលទ្ធភាពដែលតួអង្គអាចប្រព្រឹត្តទៅ ប៉ុន្តែមិនមែននៅក្នុងបរិបទមួយដែលមានភាពដាច់ខាតឡើយ។

ចំនុចទាំងពីរដែលធ្វីឱ្យរបាំមានលក្ខណៈរង្វើលនេះហើយ ដែលបង្ហាញឱ្យពីភាពអត់អោន និងចុះសំរុងរវាងតួអង្គនិងតួអង្គ អ្នកភូមិ និងអ្នកភូមិ ដែលមិនរឹតត្បិតចំពោះតួនាទីយេនឌ័រ (ការផ្លាស់ប្តូរ និងការជំនួសតួអង្គ) មិនថាក្នុងរបាំ ឬក៏នៅក្នុងភូមិផងរបស់គេ។

## ៣. ភាពមិនចាំបាច់មានលក្ខណៈជារួមធំមួយ

លក្ខណៈរង្វើលមួយទៀតនៃ*របាំរាំថ្វាយអ្នកតា* គឺការដែលមិនលុបបំបាត់ភាពជាឯកលក្ខណៈនៃសិល្បករ សិល្បការី ដើម្បីសម្រេចបានជាលក្ខណៈរួម ហើយធំមួយ។ យើងមើលឃើញថា ការមិនរឹតត្បិតចំពោះអាយុ យេនឌ័រ ជំនួសនិងបំលាស់ប្តូរតួអង្គ សុទ្ធតែជាសមាសធាតុផ្សេងៗដែលធ្វើឱ្យលក្ខណៈរង្វើលកើតឡើង។ ដូចនេះ ចំពោះការដែលមិនលុបបំបាត់ភាពជាឯកលក្ខណៈ រឹតតែធ្វើឱ្យរបាំនេះមានលក្ខណៈជារង្វើលកាន់តែខ្លាំង ។ ត្រង់ន័យនេះ "ការមិនលុបបំបាត់ភាពជាឯកលក្ខណៈ" ស្មើនឹង ពាក្យថា "ភាពមិនចាំបាច់ជារួមជាធំ" មួយ ដែលខាងក្រោមនេះនឹងចែកជា២ចំនុចតូចៗតទៀត។

ភាពមិនចាំបាច់ជារួមធំ ដែលអាចកត់សម្គាល់ច្បាស់លាស់ទី១នៅក្នុងរបាំគឺ អ្នករាំមុខសក្ការៈ អ្នកវាយគុនដំបង និងអ្នករាំដង្វាយ រមែងមិននៅសភាព និងកម្រិតដូចគ្នា។ នៅពេលដែលភ្លេងចាប់ផ្តើមលេង តួអង្គទាំងនោះបញ្ចេញកាយវិការតាមបទភ្លេង ដោយក្រុមអ្នករាំមុខសក្ការៈចាប់ផ្តើមមុនគេ បន្ទាប់មកក្រុមក្មេងប្រុសចាប់ផ្តើមវាយដំបង ឯក្រុមមនុស្សស្រីរាំដង្វាយចាប់ផ្តើមចេញរាំមកថ្វាយចុងក្រោយគេ។ ប៉ុន្តែពួកគេមិនរាំ "ស្រុះគ្នា" នៅក្នុងចង្វាក់តែមួយទេ។ ការធ្វើបៀបនេះ ក្រៅពីបង្ហាញឱ្យឃើញពីឯកលក្ខណៈនៃក្រុមដែលខ្លួនរាំ (ប្រសិនយើងចែក អ្នករាំមុខសក្ការៈ អ្នកវាយគុនដំបង និង អ្នករាំដង្វាយជាបី ក្រុមឯករាជ្យផ្សេងៗគ្នាទៀត) ហើយថែមទាំងបង្ហាញឱ្យឃើញពីលក្ខណៈរង្វើលដែល **ថ្វីត្បិតតែយើងនៅក្នុងក្រុមធំតែមួយមែន ប៉ុន្តែយើងក៏មិនចាំបាច់ដូចតែគ្នារហូត** នៃទស្សនវិជ្ជាផងដែរ។

ភាពមិនចាំបាច់ជារួមធំមួយទៀត ដែលអាចកត់សម្គាល់ច្បាស់លាស់ទី២គឺ រូបរាងភិនភាគលក្ខណៈ និងសម្រស់នៃអ្នករបាំមិនមានលក្ខណៈជារួម —— ពោលគឺតួអង្គនីមួយៗស្ថិតនៅក្នុងវ័យ

ភេទ ពណ៌សម្បុរផ្សេងៗគ្នា ដែលធ្វើឱ្យភាពជាឯកលក្ខណៈរបស់បុគ្គលម្នាក់ៗលេចធ្លោ ហើយបញ្ចេញពន្លឺកិរិយាដែលខ្លួនជាឯកលក្ខណៈ។ ជាក់ស្តែងនៅក្នុង *របាំរាំថ្វាយអ្នកតា* នេះ មានតាំងពីកុមារា កុមារី រហូតដល់បុរសស្ត្រីវ័យកណ្តាល រហូតដល់វ័យចំណាស់។ ភាពខុសគ្នាឆ្ងាយនៃអាយុនិងសម្ផស្ស ព្រមទាំងការបញ្ចេញទេពកោសល្យរបស់មនុស្សនីមួយៗ ជាហេតុធ្វើឱ្យរបាំទាំងមូលមានសភាពលក្ខណៈរង្វើលខ្លាំង។ ក្រៅពីនេះទៀត គ្រឿងលំអខ្លួនដែលជាអត្តសញ្ញាណនៃជនជាតិ "កួយ" ក៏មិនមានភាពដូចគ្នា។ ឧទា. ខ្សែកដែលធ្វើពីអង្កាំ មានពណ៌ក្រហម,ផ្កាឈូក, មាស... របស់អ្នកសម្តែងប្រុសស្រីក៏ មិនមាន ពណ៌ ទំហំ និង ប្រវែងស្មើគ្នា។ ចំនែកឯក្រវិលរបស់មនុស្សស្រីដែលធ្វើពីរុក្ខជាតិក្រៀមម្យ៉ាង ក៏មិនមានទំហំ និងប្រវែងស្មើគ្នាដែរ។ ចំនុចពីរនេះមិនត្រឹមតែបង្ហាញឱ្យឃើញពីការឱ្យតម្លៃទៅវត្ថុដោយធ្វើនឹងដៃទេ (មួយគ្មានពីរ) ថែមទាំងបង្ហាញឱ្យឃើញពី "ភាពចម្រុះសម្បូរបែប" ដែលកើតមានឡើងក្នុងធម្មជាតិផងដែរ ហើយវានឹងអាចផ្ទុយស្រឡះទៅនឹងបទដ្ឋាននៃរបាំ "ស្តង់ដារ" ដែលគេភាគច្រើនកំនត់យកសិល្បករ សិល្បការី មានរូបរាងភិនភាគ សម្ផស្ស ថែមទាំងគ្រឿងលំអខ្លួនដូចគ្នាផងដែរ។

ស្របជាមួយគ្នានេះដែរ ដូចដែលខាងលើបានប្រើប្រាស់ពាក្យថា "មិនចាំបាច់ជា" ។ ឃ្លាខាងលើគឺមិនធ្វើការបដិសេធចោល ការដែលពួកគេមិនស្រុះគ្នា វេញជាថ្លុងមួយទេ ព្រោះថាជាក់ស្តែងនៅក្នុងរបាំ នៅពេលដែលភ្លេងប្រគំដល់កន្លែងប្រសព្វគ្នាមួយ អ្នករាំសែនគ្រូ អ្នកវាយគុនដំបង និងអ្នករាំជង្វាយបានឆ្លោះសំដៅរកគ្នា ដោយសំឡេងភ្លេង និងកាយវិការដូចគ្នា ប៉ុន្តែគ្រាន់តែភាគច្រើននៃពួកគេ គឺរមែងបន្តនូវកិរិយាដែលមិនមានភាពជារួមគ្នា។

ដូចនេះ សរុបមកជារួម ដូចដែលអ្វីបានបកស្រាយ ភាពមានលក្ខណៈជារង្វើល ឬមិនចាំបាច់មានលក្ខណៈជារួមមួយ បានឱ្យយើងមើលឃើញពី **បុព្វចរិយានៃជនជាតិ "កួយ" ដែលពោរពេញទៅដោយជីវភាព និងវប្បធម៌តាមរយៈសាច់រឿងរបាំ (ជំងឺ); ការបន្តវេនតាមរយៈការលាយឡំដោយក្មេងប្រុសក្មេងស្រីដែលកុលសម្ព័ន្ធដើមនិយមគោរពទំនៀមទម្លាប់ *ទំពាំងស្នងឫស្សី* និងការបង្ហាញអត្តសញ្ញាណក្នុងព្រៃតាមរយៈការសែនព្រេនដោយមានចាស់ព្រឹទ្ធាចារ្យ ជាអ្នកដឹកនាំ និងការប្រើប្រាស់សម្ភារដែលផលិតចេញពីធម្មជាតិ។** ដូចនេះ ប្រសិនបើយើងយកលក្ខណៈទាំងអំបាលម៉ាននេះទៅមើលឱ្យឆ្ងាយជាងនេះ នោះយើងប្រទះឃើញថាការដែលមិនទាមទារភេទ អាយុ ពណ៌សម្បុរ តួអង្គ....នៃនាដករ និងនាដការីឱ្យមានភាពជារួមនេះ គឺកំពុងតែបកស្រាយនូវអត្ថន័យនៃពាក្យថា «កួយ» (ដែលមានន័យថាជា **មនុស្ស** ជាភាសាខ្មែរ) នេះឯង។ ហើយលក្ខណៈ

នេះទៀតសោតនៅក្នុងរបាំ គឺមិនត្រឹមតែកំពុងបង្ហាញឱ្យយើងឃើញពីភាពមិនមានក្រឹត្យក្រម ឬច្បាប់ដ៏មុឺងម៉ាត់មួយសម្រាប់រឹតបន្តឹង ថែមទាំងរុញបង្ហាញឱ្យយើងមើលឃើញពីធម្មជាតិ បុព្វចរិយានៃសង្គមមនុស្សដើមតាមរយៈ *របាំរាំសែនគ្រូ* ដែលពោរពេញទៅដោយភាពចុះសំរុង អត់អោន ហើយកំពុងឆ្លងកាត់ការវាយដំពត់បែនឱ្យក្លាយជាសម្ព័ន្ធដែលមាន “អរិយធម៌ក្រឹត្យក្រម” មួយ៕


រៀបចំដោយ

ឧបត្ថម្ភដោយ

ដៃគូផ្សព្វផ្សាយ

សហការឧបត្ថម្ភដោយ

គាំទ្រដោយ